ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ: ៣៨៥២ មស.សជ៣

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រឡងប្រជែងជ្រើសរើសបេក្ខជនសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល ឱ្យចូលបម្រើការងារ ក្នុងក្របខណ្ឌក្រសួងមុខងារសាធារណៈ ក្រសួងយុត្តិធម៌ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងពាណិជ្ជកម្ម សម្រាប់ឆ្នាំ២០១៨

**យោង៖** - លិខិតលេខ៤០៤៤ មស.ក្រខ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់ក្រសួងមុខងារសាធារណៈ
- ប្រកាសលេខ ៣៤០៣ មស.ប្រក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៨ របស់ក្រសួងមុខងារសាធារណៈ
- យោងតាមការចាំបាច់ និងសំណូមពរការងារ។

ក្រសួងមុខងារសាធារណៈ សូមជូនដំណឹងដល់សិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល ទាំងអស់ឱ្យបានជ្រាបថា ក្រសួងមុខងារសាធារណៈ សម្រេចបើកឱ្យមានការប្រឡងប្រជែងជ្រើសរើសសិស្ស និស្សិតនិងមន្ត្រីរាជការស៊ីវិលសរុប ចំនួន ៤៦កន្លែង ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួង ស្ថាប័ន ទាំង០៤ សម្រាប់ឆ្នាំ២០១៨ រួមមាន៖

**១-ក្រសួងមុខងារសាធារណៈ** ចំនួន ០៥កន្លែង សម្រាប់បេក្ខជនប្រឡងក្របខណ្ឌប្រភេទ **ក** ត្រូវមាន សញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្រឡើងទៅ ឬ សញ្ញាបត្រសមមូល។

**២-ក្រសួងយុត្តិធម៌** ចំនួន ០១កន្លែង សម្រាប់បេក្ខជនប្រឡងក្របខណ្ឌប្រភេទ **ក** ត្រូវមានសញ្ញាបត្រ ជំនាញហិរញ្ញវត្ថុ ឬគណនេយ្យ ចាប់ពីកម្រិតបរិញ្ញាបត្រឡើងទៅ ឬ សញ្ញាបត្រសមមូល។

**៣-ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍** ចំនួន ២០កន្លែង សម្រាប់បេក្ខជនប្រឡងក្របខណ្ឌ ប្រភេទ **ក** ត្រូវមានសញ្ញាបត្រ ជំនាញ គ្រប់គ្រង ហិរញ្ញវត្ថុ គណនេយ្យ និងសង្គមវិទ្យា ចាប់ពីកម្រិតបរិញ្ញាបត្រឡើងទៅ ឬ សញ្ញាបត្រសមមូល។ ដូចមានបែងចែកតាមអង្គភាពខាងក្រោម៖

| ល.រ | អង្គភាព | ចំនួនជ្រើសរើស | ប្រភេទក្របខណ្ឌ |
|---|---|---|---|
| **ទីស្តីការក្រសួង** | | | |
| ១ | នាយកដ្ឋានរដ្ឋបាល | ០១ | **ក** |
| ២ | នាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល | ០២ | **ក** |
| **មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្ត** | | | |
| ១ | តាកែវ | ០១ | **ក** |
| ២ | កំពត | ០១ | **ក** |
| ៣ | កែប | ០១ | **ក** |
| ៤ | ប៉ៃលិន | ០៣ | **ក** |



ផ្លូវវិថីអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

| ល.រ | អង្គភាព | ចំនួនជ្រើសរើស | ប្រភេទក្របខណ្ឌ |
|---|---|---|---|
| ៥ | សៀមរាប | ០១ | **ក** |
| ៦ | កំពង់ចាម | ០១ | **ក** |
| ៧ | ត្បូងឃ្មុំ | ០១ | **ក** |
| ៨ | ក្រចេះ | ០១ | **ក** |
| ៩ | ព្រៃវែង | ០១ | **ក** |
| ១០ | ស្វាយរៀង | ០២ | **ក** |
| ១១ | ពោធិ៍សាត់ | ០១ | **ក** |
| ១២ | បាត់ដំបង | ០៣ | **ក** |

**៤-ក្រសួងពាណិជ្ជកម្ម** ចំនួន ២០កន្លែង សម្រាប់បេក្ខជនប្រឡងក្របខណ្ឌប្រភេទ **ក** ត្រូវមានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្រឡើងទៅ ឬ សញ្ញាបត្រសមមូល។ បេក្ខជនប្រឡងក្របខណ្ឌប្រភេទ **ខ** ត្រូវមានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្ររងឡើងទៅ ឬ សញ្ញាបត្រសមមូល ដូចមានបែងចែកតាមអង្គភាពខាងក្រោម៖

| ល.រ | អង្គភាព | ក្របខណ្ឌផ្តល់ជូន | | ជំនាញជ្រើសរើស |
|---|---|---|---|---|
| | | **ក** | **ខ** | |
| I. **ទីស្តីការក្រសួង** | | | | |
| ១ | នាយកដ្ឋានបុគ្គលិក | ០១ | | គ្រប់គ្រងទូទៅ សេដ្ឋកិច្ច ពាណិជ្ជកម្ម គណនេយ្យ ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា |
| ២ | នាយកដ្ឋានគណនេយ្យ | ០១ | | គណនេយ្យ ហិរញ្ញវត្ថុ ធនាគារ |
| ៣ | នាយកដ្ឋានផែនការ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម | ០១ | | ព័ត៌មានវិទ្យា គ្រប់គ្រងទូទៅ សេដ្ឋកិច្ច ពាណិជ្ជកម្ម គណនេយ្យ ហិរញ្ញវត្ថុ |
| ៤ | នាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម | ០១ | | គ្រប់គ្រងទូទៅ សេដ្ឋកិច្ច ពាណិជ្ជកម្ម គណនេយ្យ ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា |
| ៥ | នាយកដ្ឋានអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក | ០១ | | ព័ត៌មានវិទ្យា គ្រប់គ្រងទូទៅ សេដ្ឋកិច្ច ពាណិជ្ជកម្ម គណនេយ្យ ហិរញ្ញវត្ថុ |
| ៦ | អគ្គនាយកដ្ឋានកាំកុងត្រូល | | ០២ | គ្រប់គ្រងទូទៅ ពាណិជ្ជកម្ម ធុរៈកិច្ច មគ្គុទេសក៍ទេសចរណ៍ សេដ្ឋកិច្ច |
| II. **មន្ទីរពាណិជ្ជកម្ម រាជធានី ខេត្ត** | | | | |
| ១ | មន្ទីរពាណិជ្ជកម្ម ខេត្តត្បូងឃ្មុំ | ០២ | | គ្រប់គ្រងទូទៅ សេដ្ឋកិច្ច ពាណិជ្ជកម្ម គណនេយ្យ ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា |
| ២ | មន្ទីរពាណិជ្ជកម្ម ខេត្តកំពង់ធំ | ០១ | | សេដ្ឋកិច្ចព័ត៌មានវិទ្យា គ្រប់គ្រងទូទៅ សេដ្ឋកិច្ច ពាណិជ្ជកម្ម គណនេយ្យ |

| ល.រ | អង្គភាព | ក្របខណ្ឌផ្តល់ជូន | | ជំនាញជ្រើសរើស |
|---|---|---|---|---|
| | | ក | ខ | |
| | | | | ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា |
| ៣ | មន្ទីរពាណិជ្ជកម្ម ខេត្តបន្ទាយមានជ័យ | ០១ | | គ្រប់គ្រងទូទៅ សេដ្ឋកិច្ច ពាណិជ្ជកម្ម គណនេយ្យ ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា |
| ៤ | មន្ទីរពាណិជ្ជកម្ម ខេត្តសៀមរាប | ០១ | | គ្រប់គ្រងទូទៅ សេដ្ឋកិច្ច ពាណិជ្ជកម្ម គណនេយ្យ ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា |
| ៥ | មន្ទីរពាណិជ្ជកម្ម ខេត្តកោះកុង | ០១ | | គ្រប់គ្រងទូទៅ សេដ្ឋកិច្ច ពាណិជ្ជកម្ម គណនេយ្យ ហិរញ្ញវត្ថុ ធនាគារ ព័ត៌មានវិទ្យា |
| ៦ | មន្ទីរពាណិជ្ជកម្ម ខេត្តស្ទឹងត្រែង | ០២ | | គ្រប់គ្រងទូទៅ សេដ្ឋកិច្ច ពាណិជ្ជកម្ម គណនេយ្យ ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា |
| ៧ | មន្ទីរពាណិជ្ជកម្ម ខេត្តព្រះវិហារ | ០១ | | គ្រប់គ្រងទូទៅ សេដ្ឋកិច្ច ពាណិជ្ជកម្ម គណនេយ្យ ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា |
| ៨ | មន្ទីរពាណិជ្ជកម្ម ខេត្តមណ្ឌលគិរី | ០១ | | គ្រប់គ្រងទូទៅ សេដ្ឋកិច្ច ពាណិជ្ជកម្ម គណនេយ្យ ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា |
| ៩ | មន្ទីរពាណិជ្ជកម្ម ខេត្តរតនគិរី | ០១ | | គ្រប់គ្រងទូទៅ សេដ្ឋកិច្ច ពាណិជ្ជកម្ម គណនេយ្យ ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា |
| ១០ | មន្ទីរពាណិជ្ជកម្ម ខេត្តប៉ៃលិន | ០២ | | គ្រប់គ្រងទូទៅ រដ្ឋបាលធុរកិច្ច សេដ្ឋកិច្ច ពាណិជ្ជកម្ម គណនេយ្យ ហិរញ្ញវត្ថុ |
| សរុប | | ១៨ | ០២ | |

**ក-លក្ខខណ្ឌជ្រើសរើស**

១. បេក្ខជនត្រូវមានសញ្ជាតិខ្មែរ និងមានអាយុយ៉ាងតិច១៨ឆ្នាំ

២. លក្ខខណ្ឌអាយុត្រូវបានកំណត់ដូចមានខាងក្រោម៖

- បេក្ខជនដែលមានកម្រិតបណ្តុះបណ្តាលចាប់ពីថ្នាក់បណ្ឌិតឡើងទៅ ត្រូវបានលើកលែងលក្ខខណ្ឌអាយុ
- បេក្ខជនដែលមានកម្រិតបណ្តុះបណ្តាលថ្នាក់បរិញ្ញបត្រជាន់ខ្ពស់ឬសមមូល ត្រូវមានអាយុច្រើនបំផុត ៤០ឆ្នាំ
- បេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រឬសមមូល ត្រូវមានអាយុច្រើនបំផុត ៣៥ឆ្នាំ
- បេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្ររងឬសមមូល ត្រូវមានអាយុច្រើនបំផុត ២៨ឆ្នាំ

៣. ចំពោះបេក្ខជនជាមន្ត្រីរាជការ ត្រូវបានលើកលែងលក្ខខណ្ឌអាយុ

បេក្ខជនជាមន្ត្រីរាជការត្រូវមានលិខិតអនុញ្ញាតឱ្យចូលរួមប្រឡងប្រជែងពីប្រធានក្រសួង ស្ថាប័នសាមី។ ក្រោយពេលប្រឡងជាប់ជាស្ថាពរ នៅតាមក្រសួង ស្ថាប័ន ឬអង្គភាពណាមួយ ហើយត្រូវបានរៀបចំផ្ទេរក្របខណ្ឌទៅកន្លែងថ្មី បេក្ខជនជាមន្ត្រីរាជការត្រូវបានរក្សាអតីតភាពការងារ ប៉ុន្តែមិនរក្សាមុខតំណែងគ្រប់គ្រងទេ។

៤. មិនប្រាសចាកសិទ្ធិខាងផ្លូវរដ្ឋប្បវេណី សិទ្ធិពលរដ្ឋ និងសិទ្ធិខាងនយោបាយ

៥. ចំពោះបេក្ខជនជានារី ជនពិការ និងអ្នករស់នៅតំបន់ដាច់ស្រយាល ត្រូវបានផ្តល់អាទិភាព និងលើកទឹកចិត្ត

៦. សញ្ញាបត្រ ឬ លិខិតបញ្ជាក់ការសិក្សាគ្រប់កម្រិតជំនាញ ត្រូវបានដាក់វិធានការដូចខាងក្រោម៖

- ករណីកេឃើញមានការក្លែងបន្លំសញ្ញាបត្រ ឬ លិខិតស្នាមផ្សេងៗ បេក្ខជននឹងត្រូវលុបឈ្មោះចេញជាស្វ័យប្រវត្តិ ទោះបីជាបេក្ខជននោះប្រឡងជាប់ក្នុងក្របខណ្ឌក្រសួង ស្ថាប័ណាមួយក៏ដោយ
- ចំពោះសញ្ញាបត្រដែលបានបញ្ចប់ការសិក្សាពីបរទេស ត្រូវយកទៅបញ្ជាក់ជាភាសាជាតិ ដោយមានការទទួល ស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

## ខ-សំណុំលិខិតចុះឈ្មោះសុំសិទ្ធិប្រឡងៈ

| | |
|---|---|
| ១. ពាក្យសុំចុះឈ្មោះប្រឡង | ចំនួន ០១ច្បាប់ |
| ២. ជីវប្រវត្តិសង្ខេបមានបិទរូបថតថ្មី (៤ x ៦) | ចំនួន ០១ច្បាប់ |
| ៣. សលាកបត្រឯកត្តជន | ចំនួន ០១ច្បាប់ |
| ៤. បង្កាន់ដៃទទួលពាក្យសុំសិទ្ធិប្រឡង | ចំនួន ០១ច្បាប់ |
| ៥. កិច្ចសន្យាការងារ (ផ្អែកតាមលក្ខខណ្ឌតម្រូវរបស់សាមីក្រសួង ស្ថាប័ន) | ចំនួន ០១ច្បាប់ |
| ៦. សេចក្តីចម្លងសញ្ញាបត្រជំនាញ | ចំនួន ០១ច្បាប់ |
| ៧. សេចក្តីថតចម្លងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ | ចំនួន ០១ច្បាប់ |
| ៨. សេចក្តីចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើត | ចំនួន ០១ច្បាប់ |
| ៩. លិខិតបញ្ជាក់សុខភាព (ក្រោយពេលប្រឡងជាប់) | ចំនួន ០១ច្បាប់ |
| ១០. លិខិតថ្កោលទោស (ក្រោយពេលប្រឡងជាប់) | ចំនួន ០១ច្បាប់ |
| ១១. លិខិតអនុញ្ញាតរបស់ប្រធានក្រសួង ស្ថាប័ន (សម្រាប់បេក្ខជនជាមន្ត្រីរាជការ) | ចំនួន ០១ច្បាប់ |

បញ្ជាក់៖ រាល់លិខិតស្នាមតម្រូវពាក់ព័ន្ធ ត្រូវមានការបញ្ជាក់ទទួលស្គាល់ជាផ្លូវការ។

## គ-វិញ្ញាសាប្រឡង

### ១. ក្រសួងមុខងារសាធារណៈ វិញ្ញាសាប្រឡងត្រូវបានកំណត់ដូចខាងក្រោម៖

- ម៉ោងទី១៖ ចំណេះដឹងទូទៅពាក់ព័ន្ធនឹងមុខងារសាធារណៈ រយៈពេល ០២ម៉ោង
- ម៉ោងទី២៖ មុខវិជ្ជាភាសាអង់គ្លេសនិងកុំព្យូទ័រ រយៈពេល ០១ម៉ោង ៣០នាទី

### ២. ក្រសួងយុត្តិធម៌ វិញ្ញាសាប្រឡងត្រូវបានកំណត់ដូចខាងក្រោម៖

- ម៉ោងទី១៖ ចំណេះដឹងទូទៅពាក់ព័ន្ធនឹងជំនាញ ហិរញ្ញវត្ថុ ឬគណនេយ្យ រយៈពេល ០២ម៉ោង
- ម៉ោងទី២៖ មុខវិជ្ជាភាសាអង់គ្លេសនិងកុំព្យូទ័រ រយៈពេល ០១ម៉ោង ៣០នាទី

### ៣. ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ វិញ្ញាសាប្រឡងត្រូវបានកំណត់ដូចខាងក្រោម៖

- ម៉ោងទី១៖ ចំណេះដឹងទូទៅពាក់ព័ន្ធនឹងមុខងារសាធារណៈ រយៈពេល ០២ម៉ោង
- ម៉ោងទី២៖ មុខវិជ្ជាពាក់ព័ន្ធនឹងជំនាញ គ្រប់គ្រង គណនេយ្យ ហិរញ្ញវត្ថុ ឬសង្គមវិទ្យា រយៈពេល ០១ម៉ោង ៣០នាទី

### ៤. ក្រសួងពាណិជ្ជកម្ម វិញ្ញាសាប្រឡងត្រូវបានកំណត់ដូចខាងក្រោម៖

- ម៉ោងទី១៖ ចំណេះដឹងទូទៅពាក់ព័ន្ធនឹងមុខងារសាធារណៈ រយៈពេល ០២ម៉ោង ចំពោះបេក្ខជនប្រឡងជ្រើសរើសមុខវិជ្ជាព័ត៌មានវិទ្យា
- ម៉ោងទី១៖ ចំណេះដឹងទូទៅពាក់ព័ន្ធនឹងជំនាញ រយៈពេល ០២ម៉ោង សម្រាប់ប្រភេទក្របខណ្ឌ **ក** និង **ខ** ចំពោះបេក្ខជនប្រឡងជ្រើសរើសមុខវិជ្ជា៖

  ១. គ្រប់គ្រងទូទៅ សេដ្ឋកិច្ច ពាណិជ្ជកម្ម ធុរៈកិច្ច និងសេដ្ឋកិច្ចព័ត៌មានវិទ្យា

  ២. គណនេយ្យ ហិរញ្ញវត្ថុ និងធនាគារ

៣. មគ្គុទេសក៍ទេសចរណ៍

- ម៉ោងទី២៖ មុខវិជ្ជាភាសាអង់គ្លេសនិងកុំព្យូទ័រ រយៈពេល ០១ម៉ោង ៣០នាទី សម្រាប់ប្រភេទក្របខណ្ឌ **ក** និង **ខ**

**ឃ-កាលបរិច្ឆេទលក់ពាក្យ ទទួលពាក្យ និងទីកន្លែងទទួលពាក្យ៖**

១. កាលបរិច្ឆេទលក់ពាក្យនិងទទួលពាក្យ ចាប់ពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ នេះតទៅរៀងរាល់ម៉ោងធ្វើការ ពេលព្រឹកចាប់ពីម៉ោង ០៨៖០០នាទី ដល់ម៉ោង ១១៖៣០នាទី និងពេលរសៀលចាប់ពីម៉ោង ១៤៖០០នាទី ដល់ម៉ោង ១៧៖០០នាទី

២. កាលបរិច្ឆេទឈប់ទទួលពាក្យនៅ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៨ វេលាម៉ោង ១៧៖០០នាទី ជាកាលបរិច្ឆេទចុងក្រោយ

៣. ទីកន្លែងលក់ពាក្យ និងទទួលពាក្យសុំសិទ្ធិប្រឡង៖

- **ថ្នាក់ជាតិ** បេក្ខជនអាចមកទិញពាក្យនិងដាក់ពាក្យ នៅនាយកដ្ឋានគ្រប់គ្រងក្របខ័ណ្ឌនៃក្រសួងមុខងារសាធារណៈ ឬនៅនាយកដ្ឋានបុគ្គលិក ក្រសួងយុត្តិធម៌ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងពាណិជ្ជកម្ម ។

- **ថ្នាក់ក្រោមជាតិ** បេក្ខជនអាចមកទិញពាក្យនិងដាក់ពាក្យ នៅមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ និងមន្ទីរពាណិជ្ជកម្ម រាជធានី ខេត្ត ពាក់ព័ន្ធ។

បញ្ជាក់៖ចំពោះបេក្ខជនដែលចង់ប្រឡងចូលក្របខណ្ឌ បម្រើការងារតាមមន្ទីរ របស់ក្រសួង ស្ថាប័ន ខាងលើ បេក្ខជនត្រូវមានអាស័យដ្ឋាន ឬទីលំនៅខេត្តទាំងនោះតែម្តង។

**បញ្ជាក់៖ - បេក្ខជនទាំងអស់ត្រូវមកដាក់ពាក្យសុំសិទ្ធិប្រឡងដោយខ្លួនឯងផ្ទាល់។**

**ង-កាលបរិច្ឆេទប្រឡង និងមណ្ឌលប្រឡង**

គណៈកម្មការរៀបចំការប្រឡងនឹងជូនដំណឹងអំពីកាលបរិច្ឆេទប្រឡង និងមណ្ឌលប្រឡងនៅពេលក្រោយ។ សូមបេក្ខជនទាំងអស់តាមដានព័ត៌មាននៅគេហទំព័ររបស់ក្រសួងមុខងារសាធារណៈតាមរយៈអាសយដ្ឋាន(www.mcs.gov.kh) និងតាមបណ្តាញគេហទំព័ររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ឬតាមបណ្តាញសង្គមហ្វេសប៊ុករបស់ក្រសួងមុខងារសាធារណៈ ( http://facebook.com/CivilServiceCambodia/ )។ សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង តំណាងក្រសួង ស្ថាប័ន ដូចខាងក្រោម៖

១. ក្រសួងមុខងារសាធារណៈ

ទូរស័ព្ទលេខ៖ ០១២ ៥៨៩ ៦៩៥ / ០១២ ៣៥១ ១១៤ / ០៧៧ ៨២៨ ២៥៣ / ០៧០ ៧៩១ ១១២

២. ក្រសួងយុត្តិធម៌

ទូរស័ព្ទលេខ៖ ០១២ ៧២៣ ២៧៧ / ០៨៧ ៤៤០ ៨៣០

៣.ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

ទូរស័ព្ទលេខ៖ ០៨៩ ៣៣៣ ៩៩៨ / ០១២ ៩៧៩ ០៧៩

http://www.mptc.gov.kh and www.facebook.com/officialmptc

៤.ក្រសួងពាណិជ្ជកម្ម

ទូរស័ព្ទលេខ៖ ០១២ ៦៤៤ ២៩៩ / ០៧៧ ៧៩៧ ៥៧៦ / ០១២ ៨៨៩ ៧៥៧

http://moc.gov.kh and http://www.facebook.com/moc.gov.kh

បេក្ខជនដែលមានចំណាប់អារម្មណ៍ សូមរួសរាន់មកទិញពាក្យសុំសិទ្ធិប្រឡងដើម្បីបំពេញសំណុំបែបបទប្រឡងប្រជែងជ្រើសរើសតាមក្រសួង ស្ថាប័ន ណាមួយដែលខ្លួនមានបំណងចង់ចូលបម្រើការងារ ដូចបានរៀបរាប់ខាងលើនេះ។

បញ្ជាក់៖ **បេក្ខជនអាចដាក់ពាក្យសុំសិទ្ធិប្រឡងបានតែមួយក្រសួង ស្ថាប័ន តែប៉ុណ្ណោះ។**

កំណត់សម្គាល់៖ ក្រសួងមុខងារសាធារណៈ សូមរក្សាសិទ្ធិកែប្រែសេចក្ដីជូនដំណឹងនេះ ក្នុងករណីចាំបាច់៕

ថ្ងៃ សុក្រ ១៤ រោច ខែទុតិយាសាឍ ឆ្នាំច សំរិទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ២០១៨

**រដ្ឋលេខាធិការនិងជា**

**ប្រធានគណៈកម្មការរៀបចំការប្រឡង**

**យូ ស៊ុនឡុង**

**ចម្លងជូន៖**

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

" ដើម្បីជូនជ្រាប "

-ក្រសួងយុត្តិធម៌

-ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

-ក្រសួងពាណិជ្ជកម្ម

-មន្ទីររាជធានី ខេត្ត គ្រប់ក្រសួង ពាក់ព័ន្ធ

" ដើម្បីសហការអនុវត្ត និងជួយផ្សព្វផ្សាយ "

-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ៣៤៥៣ មស.សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការកំណត់លក្ខណៈវិនិច្ឆ័យ
## នៃការប្រឡងប្រជែងជ្រើសរើសសិស្ស និស្សិតនិងមន្ត្រីរាជការស៊ីវិល ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងមុខងារសាធារណៈ ក្រសួងយុត្តិធម៌ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងពាណិជ្ជកម្ម សម្រាប់ឆ្នាំ២០១៨

## រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- យោងលិខិតលេខ៤០៤៤ មស.ក្រខ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់ក្រសួងមុខងារសាធារណៈ
- លិខិតលេខ០៧៧២ កយ.បល/១៨ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៨ របស់ក្រសួងយុត្តិធម៌
- លិខិតលេខ០៧១៤ បទ.បប ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨ របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- លិខិតលេខ២៦៦២ ពណ.បល ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៨ របស់ក្រសួងពាណិជ្ជកម្ម
- សេចក្ដីជូនដំណឹងលេខ ៣៤៥២ មស.សជណ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៨ របស់ក្រសួងមុខងារសាធារណៈ
- យោងតាមការចាំបាច់ និងសំណូមពរការងារ។

## សម្រេច

**ប្រការ ១ ៖** បើកឱ្យមានការប្រឡងប្រជែងជ្រើសរើសសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល ទូទាំងព្រះរាជាណាចក្រកម្ពុជា ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួង ស្ថាប័នទាំងបួន ដែលមានលក្ខណៈសម្បត្តិសមស្របតាមកម្រិតក្របខណ្ឌ **ក** និង**ខ** សម្រាប់ឆ្នាំ២០១៨ តាមចំនួនបែងចែកដូចខាងក្រោម៖

| | |
|---|---|
| ១-ក្រសួងមុខងារសាធារណៈ | ចំនួន ០៥ កន្លែង |
| ២-ក្រសួងយុត្តិធម៌ | ចំនួន ០១ កន្លែង |
| ៣-ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ចំនួន ២០ កន្លែង |
| ៤-ក្រសួងពាណិជ្ជកម្ម | ចំនួន ២០ កន្លែង |



ផ្លូវវិត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

**ប្រការ ២ ៖** ការប្រឡងប្រជែងជ្រើសរើសសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងមុខងារសាធារណៈ ក្រសួងយុត្តិធម៌ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងពាណិជ្ជកម្ម សម្រាប់ផែនការក្របខណ្ឌ ឆ្នាំ២០១៨ នេះ **ចាត់ទុកជាការប្រញាប់។**

**ប្រការ ៣ ៖** លក្ខណៈវិនិច្ឆ័យនានាជាលម្អិត ពាក់ព័ន្ធទៅនឹងការប្រឡងប្រជែងខាងលើនេះ ត្រូវកំណត់ដោយគណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល ឱ្យចូលបម្រើការងារក្នុងក្រសួង ស្ថាប័នទាំងបួន។

**ប្រការ ៤ ៖** អគ្គនាយកនៃអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានគ្រប់គ្រងក្របខ័ណ្ឌនៃក្រសួងមុខងារសាធារណៈ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវសហការ និងទទួលបន្ទុកអនុវត្តតាមសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ សុក្រ ១៤រោច ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ២០១៨

**រដ្ឋលេខាធិការនិងជា**

**ប្រធានគណៈកម្មការរៀបចំការប្រឡង**

យូ ស៊ុនឡុង

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

" ដើម្បីជូនជ្រាប "

-ក្រសួងយុត្តិធម៌

-ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

-ក្រសួងពាណិជ្ជកម្ម

" ដើម្បីសហការអនុវត្ត "

-ដូចប្រការ៤ (ដើម្បីអនុវត្ត)

-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ: ៣៤៥៩ មស.ក្រ

ថ្ងៃ សុក្រ ១៤រោច ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៨

# បទបញ្ញត្តិ

## សម្រាប់បេក្ខជនប្រឡងប្រជែងចូលបម្រើការងារក្នុងក្របខណ្ឌក្រសួង ស្ថាប័ន ទាំងមូល ឆ្នាំ២០១៨

ដើម្បីរក្សាសណ្តាប់ធ្នាប់របៀបរៀបរយ និងវិន័យនៅក្នុងពេលប្រឡងឱ្យប្រព្រឹត្តទៅបានល្អប្រសើរ បេក្ខជនត្រូវគោរពតាមបទបញ្ញត្តិនៃការប្រឡង ដូចខាងក្រោម៖

១. ប្រការដែលបេក្ខជនត្រូវអនុវត្ត

- ត្រូវមកដល់មណ្ឌលប្រឡង មុនចាប់ផ្តើមដំណើរការប្រឡងរយៈពេល ៣០នាទី
- ត្រូវស្លៀកសំលៀកបំពាក់សមរម្យ
- ត្រូវយកមកជាមួយនូវសលាកប័ត្រឯកត្តជន អត្តសញ្ញាណប័ណ្ណ ឬ ប័ណ្ណសំគាល់ខ្លួនសិស្ស និស្សិត
- ត្រូវអនុវត្តតាមការណែនាំរបស់ប្រធានអនុគណៈកម្មការមេប្រយោគ និងប្រធានអនុគណៈកម្មការអនុរក្ស
- ត្រូវរក្សារបៀបរៀបរយ និងភាពស្ងៀមស្ងាត់នៅក្នុងពេលប្រឡង
- ត្រូវប្រើប៊ិចឃ្លីដែលមានទឹកពណ៌ខៀវ
- បេក្ខជនត្រូវបង្កលក្ខណៈងាយស្រួលឱ្យអ្នកមានសមត្ថកិច្ចត្រួតពិនិត្យ ហើយត្រូវគោរពតាមសំណូមពររបស់អ្នកត្រួតពិនិត្យក្នុងការដកហូតនូវសម្ភារៈ ឬ របស់អ្វីៗដែលគ្មានការអនុញ្ញាតឱ្យយកចូលក្នុងបន្ទប់ប្រឡង
- ត្រូវគោរពវិន័យនៃការប្រឡងដោយមិនត្រូវធ្វើឱ្យខូចរបៀបរៀបរយនិងសណ្តាប់ធ្នាប់នៃការប្រឡងដូចជា បេក្ខជនត្រូវអង្គុយតាមលេខតុដែលអនុរក្សបង្ហាញ សរសេរឈ្មោះនិងលេខតុនៅលើក្បាលសន្លឹកកិច្ចការប្រឡងដែលអនុរក្សចែកជូន និងប្រគល់សន្លឹកកិច្ចការប្រឡងជូនអនុរក្សប្រចាំបន្ទប់វិញ ទោះបីជាសន្លឹកកិច្ចការប្រឡងនោះមិនសរសេរចម្លើយ ឬ ដំណោះស្រាយអ្វីក៏ដោយ។ បេក្ខជនដែលមិនប្រគល់សន្លឹកកិច្ចការប្រឡងជូនអនុរក្សវិញ ត្រូវចាត់ទុកថាអវត្តមាន។

២. ប្រការដែលបេក្ខជនមិនត្រូវអនុវត្ត

- ហាមដាច់ខាតសេពគ្រឿងស្រវឹង
- ហាមយកអាវុធ ឬ គ្រឿងផ្ទុះគ្រប់ប្រភេទចូលក្នុងមណ្ឌលប្រឡង
- ហាមយកតាម និងប្រើប្រាស់ទូរស័ព្ទ វិទ្យុទាក់ទងគ្រប់ប្រភេទ និងឧបករណ៍អេឡិចត្រូនិចគ្រប់ប្រភេទដែលមានផ្ទុកឯកសារចូលក្នុងបន្ទប់ប្រឡង
- មិនត្រូវឱ្យអ្នកដទៃប្រឡងជំនួសឡើយ
- ហាមចម្លងចម្លើយពីអ្នកជិតខាង ឬ បង្កលក្ខណៈឱ្យអ្នកដទៃចម្លង ឬ សរសេរហើយអានខ្លាំងៗឮដល់បេក្ខជនដទៃទៀតក្នុងពេលកំពុងធ្វើវិញ្ញាសា
- ហាមប្តូរសន្លឹកកិច្ចការប្រឡង ដើម្បីឱ្យអ្នកដទៃជួយកែ និងមិនត្រូវស្នើឱ្យអ្នកដទៃជួយពន្យល់
- ហាមប្រើទឹកលុបសម្រាប់លុបកំហុសផ្សេងៗ លើសន្លឹកកិច្ចការប្រឡង

បញ្ជាក់៖ រាល់ការប្រព្រឹត្តល្មើសនឹងបទបញ្ញត្តិខាងលើ កម្រិតពិន័យត្រូវបានកំណត់ដោយប្រធានអនុគណៈកម្មការមេប្រយោគ។

រដ្ឋលេខាធិការ និងជា
ប្រធានគណៈកម្មការរៀបចំការប្រឡង

ឃូ ស៊ុនឡុង